ខ និងលក្ខខណ្ឌ
សេវាកម្មអាជីវកម្ម

មាតិកា

១.	និយមន័យ	២
២.	ប្រតិបត្តិការទូទាត់ និងទទួលទូទាត់	៧
	២.១. ការទទួលយកការទូទាត់	៧
	២.២. ប្រតិបត្តិការកាត់ទុក	៨
	២.៣. ការដំណើរការប្រតិបត្តិការ	៨
	២.៤. ការដកយកកាត និងការរក្សាទុក	៨
៣.	ការអនុញ្ញាតប្រតិបត្តិការកាត	៩
៤.	ការទូទាត់ និងការផ្ដាត់ទាត់	៩
៥.	បង្កាន់ដៃលក់ដូរ	១០
៦.	ការការពារអ្នកប្រើប្រាស់	១០
៧.	ការរក្សាទុក និងការបញ្ជូនទិន្នន័យកាត និងបង្កាន់ដៃលក់ដូរ	១១
៨.	ការត្រួលប់ និងការកែតម្រូវ	១១
៩.	ការទទួលខុសត្រូវចំពោះប្រតិបត្តិការទូទាត់	១២
១០.	ការអនុលោមតាមច្បាប់	១២
១១.	អាជីវកម្មរបស់អាជីវករ	១៣
១២.	ការផ្សព្វផ្សាយ និងប្រូម៉ូសិន	១៤
១៣.	ការជូនដំណឹងអំពីកំហុសឆ្គង	១៤
១៤.	វិសោធនកម្មលើកិច្ចព្រមព្រៀង	១៤
១៥.	ការធានា	១៤
១៦.	ការបញ្ចប់កិច្ចព្រមព្រៀង និងវិបាក	១៥
១៧.	សំណង និងការទទួលខុសត្រូវមានកម្រិត	១៦
១៨.	ការផ្ទេរសិទ្ធិបន្ត	១៧
១៩.	កិច្ចព្រមព្រៀងទាំងស្រុង	១៧
២០.	អសុពលភាពដោយផ្នែក	១៧
២១.	ច្បាប់គ្រប់គ្រង	១៧
២២.	ការដោះស្រាយវិវាទ	១៧

ខ និងលក្ខខណ្ឌសេវាកម្មអាជីវករ

ខ និងលក្ខខណ្ឌសេវាកម្មអាជីវកររនេះ គួរតែអានឲ្យបានលម្អិតច្បាស់លាស់ បន្ថែមពីលើ កិច្ចព្រមព្រៀងសេវាកម្មអាជីវករ។

ដោយពិចារណាលើ ខ និងលក្ខខណ្ឌ ដែលបានចែងខាងក្រោម និងមានបំណងក្នុងការចងកាតព្វកិច្ចដោយបញ្ញត្តិនៃខ និងលក្ខខណ្ឌសេវាកម្មអាជីវកររនេះ ធនាគារ ABA និងអាជីវករ យល់ព្រមដូចខាងក្រោម។

១. និយមន័យ

"កម្មវិធី ABA Mobile"	មានន័យថា កម្មវិធីសម្រាប់ឧបករណ៍ចល័ត ដែលអាចដោនឡូតបានដោយម្ចាស់គណនី ABA ពីទីកន្លែងដែលបានកំណត់ ឬកន្លែងស្វែងរក/លក់កម្មវិធី (application store) ដើម្បីធ្វើការទូទាត់ ទៅអាជីវករ ដែលតទៅនេះ ហៅកាត់ថា "ABA Mobile ឬ ABA App"។
"អ្នកប្រើ ABA Mobile App"	មានន័យថា ម្ចាស់គណនី ABA ដែលកំពុងប្រើប្រាស់ ABA Mobile ហើយបានទទួលយកខ និងលក្ខខណ្ឌ ឬលក្ខខណ្ឌប្រើប្រាស់កម្មវិធី ABA Mobile។
"ABA Pay"	សំដៅលើមុខងារទូទាត់នៅលើកម្មវិធី ABA Mobile ដែលត្រូវបានប្រើសម្រាប់ស្កែនកូដ QR ដែលបង្កើតដោយម៉ាស៊ីនទូទាត់ POS។
"KHQR"	សំដៅលើ មុខងារទូទាត់ ដែលបានបង្កើតឡើង សម្រាប់ផ្នែកទូទាត់រាយ នៅក្នុងប្រទេសកម្ពុជា។ វាតម្រូវឲ្យមានកូដ QR រួមតែមួយប៉ុណ្ណោះ សម្រាប់ទទួលប្រាក់ទូទាត់ពីអេបធនាគារនានា ព្រមទាំងអេបបាគង ដែលធ្វើឲ្យការទូទាត់តាម QR ងាយស្រួល សម្រាប់អតិថិជន និងអាជីវកររនៅក្នុងប្រទេសកម្ពុជា។
"ការទូទាត់តាម QR"	មានន័យថា មុខងារទូទាត់ នៅលើអេបរបស់ អ្នកបង់ប្រាក់ ដែលពួកគាត់អាចធ្វើការទូទាត់ដោយស្កែនកូដ QR ដែលបង្ហាញនៅហាងរបស់អាជីវករ។
"ABA QR"	សំដៅលើ កូដ QR ដែលបង្កើតឡើង ឬព្រីន និងផ្តល់ជូនដោយធនាគារ ABA។ កូដនេះ អនុញ្ញាតឲ្យអាជីវករទទួលប្រាក់ទូទាត់តាមរយៈការស្កែន QR។
"WeChat"	សំដៅលើកូដ QR ដោយប្រើអេប WeChat ឬត្រូវបានព្រីន និងផ្តល់ជូនដោយធនាគារ ABA។ កូដនេះ អនុញ្ញាតឲ្យអាជីវករទទួលប្រាក់ទូទាត់តាមរយៈការស្កែន QR។

“Alipay”	សំដៅលើកូដ QR ដោយប្រើអេប Alipay ឬត្រូវបានព្រីន និងផ្តល់ជូនដោយធនាគារ ABA។ កូដនេះ អនុញ្ញាតឲ្យអាជីវករទទួលប្រាក់ទូទាត់តាមរយៈការស្កែន QR។
“Alipay+”	សំដៅលើការទូទាត់ចូលពី Alipay CN និងដៃគូទូទាត់ Ant International តាមរយៈបណ្តាញ ABA KHQR ដោយផ្តល់អត្ថប្រយោជន៍ជាសាវន្តជូនអាជីវករ ABA។
“កូដ QR ចរន្ត”	សំដៅលើកូដ QR ដែលបង្កើតឡើង និងបង្ហាញនៅលើម៉ាស៊ីនទូទាត់ POS សម្រាប់ទទួលប្រាក់ទូទាត់តាមរយៈការស្កែន QR។
“កិច្ចព្រមព្រៀង”	សំដៅលើ ពាក្យស្នើសុំរបស់អាជីវករ ខនិងលក្ខខណ្ឌទាំងនេះ ព្រមទាំងលក្ខខណ្ឌទាំងអស់ដែលបានកំណត់ មានជាអាទិ៍ កាលវិភាគនៃថ្លៃសេវា ឯកសារបន្ថែមណាមួយដែលបានបញ្ជាក់ទីនេះ ដូចដែលបានធ្វើវិសោធនកម្ម ពីពេលមួយទៅពេល ដែលចំណុចទាំងអស់នេះ បង្កើតបានជាកិច្ចព្រមព្រៀងអាជីវករ។
“គណនី”	មានន័យថា គណនីធនាគារដែលបានរក្សាទុកដោយអាជីវករ សម្រាប់ដាក់ទឹកប្រាក់ដែលប្រមូលបាន និងសម្រាប់ដកប្រាក់ទូទាត់ថ្លៃសេវា និងបន្ទុកផ្សេងៗទៀត ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ។
“ពាក្យស្នើសុំ”	មានន័យថា ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរ ដោយអាជីវករដែលស្នើទៅ ABA រួមមាន ការរៀបរាប់បញ្ជាក់អំពីអាជីវកម្មរបស់អាជីវករ លក្ខណៈ និងការប្រព្រឹត្តទៅនៃអាជីវកម្ម និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដើម្បីឲ្យ ABA បង្កើតកិច្ចព្រមព្រៀងនេះឡើង។
“ការអនុញ្ញាតប្រតិបត្តិការ”	មានន័យថា ការអនុម័ត ដែលផ្តល់ជូនដោយមុខងារកុំព្យូទ័រ ឬការហៅទូរស័ព្ទទៅលេខដែលបានកំណត់ដោយផ្ទាល់ ដើម្បីទទួលបានការអនុម័ត សម្រាប់ប្រតិបត្តិការបុគ្គល ពីក្រុមហ៊ុនចេញកាត។
“ភ្នាក់ងារមានសិទ្ធិអនុញ្ញាត”	មានន័យថា បុគ្គលដែលទទួលបានសិទ្ធិអនុញ្ញាតពីអាជីវករ ដើម្បីធ្វើជាតំណាងរបស់អាជីវករ សម្រាប់រាល់បញ្ហាទាំងអស់ ដែលទាក់ទងនឹងកិច្ចព្រមព្រៀងនេះ។
“អ្នកចេញកាត”	សំដៅលើគ្រឹះស្ថានហិរញ្ញវត្ថុ ឬក្រុមហ៊ុនដែលបានផ្តល់កាតជូនម្ចាស់កាត។
“បណ្តាញកាត ឬប្រព័ន្ធទូទាត់”	សំដៅលើក្រុមហ៊ុន Visa, MasterCard ឬក្រុមហ៊ុនចេញកាតផ្សេងទៀត ដែលផ្តល់កាត ហើយកាតនោះត្រូវបានទទួលយកដោយអាជីវករ តាមរយៈកិច្ចព្រមព្រៀងជាមួយធនាគារ ABA និងអាជីវករ។

“កាត”	សំដៅលើកាតឥណទាន និង/ឬឥណពន្ធមានសុពលភាព ក្នុងទម្រង់ដែលចេញក្រោមអាជ្ញាប័ណ្ណពីក្រុមហ៊ុន Visa International, MasterCard International, UnionPay International (UPI), Japan Credit Bureau (JCB) ឬកាតឥណទាន និង/ឬឥណពន្ធមានសុពលភាពណាមួយផ្សេងទៀត ដែលទទួលយកដោយអាជីវករ តាមរយៈកិច្ចព្រមព្រៀងជាមួយធនាគារ ABA និងអាជីវករ។
“ម្ចាស់កាត”	មានន័យថា បុគ្គលដែលមានឈ្មោះនៅលើផ្ទៃកាត ហើយបញ្ជាក់ថាជាឈ្មោះដែលត្រូវបានចេញកាតជូន។
“កម្មវិធីសន្តិសុខព័ត៌មានម្ចាស់កាត (CISP)”	គឺជាកម្មវិធីដែលបង្កើតឡើងដោយប្រព័ន្ធទូទាត់ ដើម្បីធានាថាព័ត៌មានរបស់ម្ចាស់កាត ត្រូវបានដំណើរការ និង/ឬក្សាទុកដោយសុវត្ថិភាព ដោយមិនមានបញ្ចេញទៅភាគីទីបី។ កម្មវិធីនេះ ក៏បង្កើនការគ្រប់គ្រងជុំវិញទិន្នន័យម្ចាស់កាត ដើម្បីកាត់បន្ថយការក្លែងបន្លំ និងការបន្លំផ្សេងៗតាមរយៈការបង្ហាញទិន្នន័យទាំងនោះផង ដែរ។
“កាតក្លែងក្លាយ”	គឺជាប្រភេទកាតក្លែងក្លាយដែលមានព័ត៌មានគណនីពិតប្រាកដ ដោយព័ត៌មាននោះត្រូវបានលួចពីជនរងគ្រោះ ហើយជនរងគ្រោះនៅតែមានកាតពិតប្រាកដរបស់ពួកគេ ដែលពួកគេពុំបានដឹងថាសកម្មភាពក្លែងបន្លំនោះកំពុងកើតឡើងនោះទេ។ កាតបង្ហាញភាពស្របច្បាប់ជាមួយនឹងឡូហ្គូរបស់ស្ថាប័នចេញកាត និងបន្ទះម៉ាញេទិកដែលបានអ៊ិនកូដ (encode)។
“ប្រតិបត្តិការ”	សំដៅលើ ការលក់រាយនៃទំនិញ និងសេវាកម្ម ឬទទួលទឹកប្រាក់ពីការលក់ទំនិញ/សេវាកម្មទាំងនោះ ដែលអាជីវករធ្វើការទូទាត់ដោយប្រើកាតណាមួយ និងបានស្នើប្រតិបត្តិការទៅធនាគារ ABA ដើម្បីធ្វើការប្រមូលប្រាក់ពីអតិថិជន។
“ប្រតិបត្តិការទូទាត់ត្រលប់ (chargeback)”	មានន័យថា នីតិវិធីដែលតម្លៃនៃការលក់ (ឬផ្នែកដែលមានបញ្ហា) ត្រូវបានប្រគល់ទៅធនាគារ ABA វិញដោយស្ថាប័នចេញកាត។
“ប័ណ្ណទឹកប្រាក់/បង្កាន់ដៃឥណទាន”	សំដៅលើ ឯកសារដែលអនុវត្ត ឬប្រើប្រាស់ដោយអាជីវករ ធ្វើជាឯកសារយោងសម្រាប់គោលបំណង ប្រគល់ប្រាក់ឲ្យអតិថិជនវិញ ឬការកែប្រែតម្លៃ ពាក់ព័ន្ធនឹងការទូទាត់តាមកាត ដែលការប្រគល់ឬកែប្រែទាំងនោះត្រូវបញ្ចូលទៅក្នុងគណនីម្ចាស់កាត។
“អតិថិជន”	សំដៅលើម្ចាស់កាតដែលទិញទំនិញ និងសេវាកម្មពីអាជីវករ ដោយប្រើកាត Visa ឬ MasterCard របស់ពួកគេ។

“អ្នកបង់ប្រាក់”	សំដៅលើអ្នកប្រើកម្មវិធីធនាគារលើទូរស័ព្ទ ABA ឬមិនមែន ABA, ម្ចាស់កាត ABA ឬមិនមែន ABA ដែលធ្វើការទូទាត់ថ្លៃទំនិញ ឬសេវាកម្ម។
“វិវាទ”	សំដៅលើ ការទាមទារណាមួយ ដែលកើតឡើងពីអ្នកប្រើប្រាស់ ABA App ឬមិនមែន ABA App ឬម្ចាស់កាត ដើម្បីប្រគល់មកវិញនូវទឹកប្រាក់ថ្លៃផលិតផល ឬសេវាកម្ម ក្នុងករណីមានប្រតិបត្តិការស្ទួនគ្នា, ផលិតផល ឬសេវាកម្មមិនត្រូវបានប្រគល់ជូន ឬមានសភាពខូចខាត។ល។ ដូចបានបញ្ជាក់នៅក្នុងនីតិវិធីដោះស្រាយវិវាទ។
“ឯកសារ/ឯកសារ MATCH”	(ការជូនដំណឹងដល់សមាជិកដើម្បីគ្រប់គ្រងអាជីវករដែលមានហានិភ័យខ្ពស់) គឺជាបញ្ជីដែលត្រូវបានចុះឈ្មោះ/ពាយការណ៍សម្រាប់សកម្មភាពអាជីវករ នៅពេលចាប់ផ្តើម/បញ្ចប់ការទទួលយកការទូទាត់តាមកាត។
“កាតទទួលទូទាត់ (Honoring Card)”	មានន័យថាកាតមានសុពលភាពទាំងអស់ ត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវសម្រាប់ប្រតិបត្តិការពិតប្រាកដ ដោយមិនអាស្រ័យលើតម្លៃ ឬឈ្មោះធនាគារដែលបង្ហាញនៅលើកាត ហើយដែលត្រូវទទួលទូទាត់ដោយអាជីវករ។
“អាជីវករ”	សំដៅលើ ធុរកិច្ចជនជាបុគ្គល អង្គភាព ឬក្រុមហ៊ុន ដែលទទួលទូទាត់តាមកាត Visa International, MasterCard International, UnionPay International (UPI), Japan Credit Bureau (JCB) ឬតាមរយៈការស្កែន QR ហើយយល់ព្រមចងកាតព្វកិច្ចដោយកិច្ចព្រមព្រៀងនេះដែលកំណត់ដោយធនាគារ ABA។
“លេខកូដប្រភេទអាជីវករ ឬ MCC”	សំដៅលើលេខកូដ ដែលប្រើសម្រាប់បែងចែកប្រភេទអាជីវករ។
“អត្រាតម្លៃប្រតិបត្តិការ”	សំដៅលើ អត្រានៃការគិតថ្លៃលើប្រតិបត្តិការទាំងអស់ ដែលត្រូវបង់ដោយអាជីវករ ទៅធនាគារ ABA សម្រាប់ការដំណើរការទូទាត់តាមរយៈម៉ាស៊ីន POS ឬស្កែន QR។
“ប្រតិបត្តិការតាមកាតធនាគារផ្សេង”	មានន័យថាកាត Visa International, MasterCard International, UnionPay International (UPI), Japan Credit Bureau (JCB) ដែលចេញដោយធនាគារផ្សេង ហើយធ្វើប្រតិបត្តិការជាមួយអាជីវកររបស់ធនាគារ ABA។

“ប្រតិបត្តិការតាមកាត ABA”	មានន័យថាកាត Visa International, MasterCard International, UnionPay International (UPI), Japan Credit Bureau (JCB) ដែលចេញដោយធនាគារ ABA ហើយធ្វើប្រតិបត្តិការជាមួយអាជីវកររបស់ធនាគារ ABA ។
“ម៉ាស៊ីនទូទាត់ POS”	មានន័យថាឧបករណ៍ដែលអាជីវកររប្រើសម្រាប់ការអនុញ្ញាតប្រតិបត្តិការអេឡិកត្រូនិក និង/ឬប្រតិបត្តិការកាត ។
“កូដ QR”	សំដៅលើ កូដ QR ថេរ និងជាប្រភេទព្រីន ដែលផ្តល់ជូនដោយធនាគារ ABA ទៅអាជីវករ សម្រាប់ទទួលទូទាត់តាមរយៈការស្កែនកូដ QR ។ កូដនោះ អាចព្រីននៅលើជើងបញ្ជរ ខ្សែកាត សន្លឹកបិទ និងឧបករណ៍ផ្សេងទៀត ដែលបង្កើតឡើងដោយ ABA ។
“ប្រតិបត្តិការទូទាត់”	សំដៅលើ ការលក់រាយនៃទំនិញ ឬសេវាកម្មណាមួយ ដែលអាជីវករធ្វើការទូទាត់ ដោយប្រើ ABA Mobile (ABA Pay), KHQR, កាត ដែលបានស្នើប្រតិបត្តិការទៅធនាគារ ABA ដើម្បីធ្វើការប្រមូលប្រាក់ពីអតិថិជន ។
“បង្កាន់ដៃលក់ដូរ”	មានអត្ថន័យ ដូចមានចែងនៅក្នុងចំណុចទី ៧ ខាងក្រោម ។
"ការអនុញ្ញាតប្រតិបត្តិការជាសំឡេង"	មានន័យថាការអនុម័ត តាមរយៈការហៅទូរស័ព្ទដោយផ្ទាល់ទៅកាន់លេខដែលបានកំណត់ ដើម្បីទទួលបានការអនុម័តលើប្រតិបត្តិការកាត ។
“កម្មវិធី ABA ចាយបានលុយ”	នៅពេលចុះឈ្មោះចូលរួមកម្មវិធី អាជីវករត្រូវបានស្នើសុំផ្តល់រូបភាព និងឡូហ្គូជាមួយគុណភាពខ្ពស់ (high resolution) ដើម្បីដាក់ទៅក្នុងបញ្ជី កម្មវិធី ABA ចាយបានលុយ ។ អាជីវករទាំងអស់ដែលចូលរួមក្នុងកម្មវិធីនេះ ត្រូវផ្តល់ជូនការបញ្ចុះតម្លៃ (%) ដល់អតិថិជន ABA ។ នេះគឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងសេវាកម្មអាជីវករ ប្រការ ១៦ ។ សូមចងចាំថា ការផ្លាស់ប្តូរណាមួយនឹងមិនត្រូវបានធ្វើឡើងឡើយ ក្នុងរយៈពេលដែលបានព្រមព្រៀងរួច ។

២. ប្រតិបត្តិការទូទាត់ និងទទួលទូទាត់

២.១. ការទទួលយកការទូទាត់

ក.) អាជីវករត្រូវកំណត់អត្តសញ្ញាណអ្នកបង់ប្រាក់ ដើម្បីកំណត់មធ្យោបាយទូទាត់ដែលអតិថិជនរបស់ពួកគាត់ អាចធ្វើការទូទាត់តាមជាមួយ ABA Pay, KHQR, QR WeChat និង QR Alipay/Alipay+ ឬកាត ដោយភាពស្មោះត្រង់ ។ សម្រាប់កាតទូទាត់ ដោយផ្អែកតាមសមត្ថភាពផ្ទាល់របស់អាជីវករត្រូវដឹងថាកាតនោះមានសុពលភាពដោយត្រួតពិនិត្យមុខងារសុវត្ថិភាពកាតយ៉ាងត្រឹមត្រូវ យកចិត្តទុកដាក់ និងប្រុងប្រយ័ត្ន តាមគោលការណ៍ណែនាំអំពីការទទួលយកបរបស់ធនាគារ ABA ។ បើមិនដូច្នេះទេ អាជីវករត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការទទួលយកកាតដែលគួរឲ្យសង្ស័យ ឬក្លែងក្លាយ ដើម្បីជំណើរការប្រតិបត្តិការ ។

ខ.) អាជីវករត្រូវទទួលទូទាត់ និងបំពេញបញ្ចប់ប្រតិបត្តិការលក់ ពីប្រតិបត្តិការទូទាត់ដោគជ័យ ដូចជាការទូទាត់តាមរយៈ ABA Pay, KHQR, QR WeChat និង QR Alipay/Alipay+ ឬកាត ជាប្រតិបត្តិការស្របច្បាប់ និងកំណត់កម្រិតទឹកប្រាក់អប្បបរមា ឬអតិបរមាសម្រាប់មធ្យោបាយទូទាត់ណាមួយ ។

គ.) អាជីវករត្រូវទទួលហត្ថលេខារបស់ម្ចាស់កាតសម្រាប់ប្រតិបត្តិការកាតទាំងអស់ លើកលែងតែប្រតិបត្តិការផ្អែកលើកូដ PIN ឬប្រតិបត្តិការចរន្តជិត (contactless) ដែលបានតម្លៃក្រោម ៥០ (ហាសិប) ដុល្លារ ។ អាជីវករត្រូវទទួលខុសត្រូវទាំងស្រុងចំពោះប្រតិបត្តិការទូទាត់ត្រលប់ (chargeback) ក្នុងករណីដែលអាជីវករមិនបានទទួលហត្ថលេខារបស់ម្ចាស់កាតត្រឹមត្រូវតាមស្ថានភាព/លក្ខខណ្ឌដែលបានរៀបរាប់ ។ កថាខណ្ឌ (គ) នេះ អនុវត្តចំពោះអាជីវករដែលចុះឈ្មោះប្រើប្រាស់សេវាកម្មម៉ាស៊ីនទូទាត់ POS ប៉ុណ្ណោះ ។

ឃ.) អាជីវករមិនត្រូវដាក់ថ្លៃសេវាណាមួយបន្ថែម ឬគិតថ្លៃបន្ថែមសម្រាប់ការទូទាត់ដោយប្រើកាតឡើយ ។ ការមិនគោរពតាមលក្ខខណ្ឌនេះ អាជីវករត្រូវទទួលខុសត្រូវចំពោះការពិន័យទាំងអស់ដែលដាក់ចេញដោយស្ថាប័នកាត ឬប្រព័ន្ធទូទាត់ ។ ឧបសម្ពន្ធ ក

ង.) អាជីវករ មិនត្រូវទទួលយកកាតណាមួយដែលផុតកំណត់ដើម្បីធ្វើប្រតិបត្តិការឡើយ និងមិនត្រូវបំពេញបញ្ចប់ប្រតិបត្តិការណាមួយឡើយ ប្រសិនបើហត្ថលេខារបស់ម្ចាស់កាតនៅលើបង្កាន់ដៃលក់ដូរខុសពីហត្ថលេខានៅលើកាត ។ កថាខណ្ឌ (ង) នេះ អនុវត្តចំពោះអាជីវករដែលចុះឈ្មោះប្រើប្រាស់សេវាកម្មម៉ាស៊ីនទូទាត់ POS ប៉ុណ្ណោះ ។

ច.) អាជីវករមិនត្រូវទទួលយក និងបំពេញបញ្ចប់ប្រតិបត្តិការទូទាត់ពីអាជីវកររផ្សេង ឬបុនហិរញ្ញប្បទានចំពោះបំណុលដែលមានស្រាប់ និង/ឬវ៉ាប់ងេទូទាត់មូលប្បទានបត្រដែលត្រូវបានបដិសេធឡើយ ។

២.២. ប្រតិបត្តិការកាត់ទុក

អាជីវករត្រូវប៉ាន់ស្មាន និងទទួលបានការអនុញ្ញាតសម្រាប់ប្រតិបត្តិការទឹកប្រាក់ ដោយផ្អែកលើរយៈពេលនៃការស្នាក់នៅ ឬប្រតិបត្តិការដូលតាមកាលកំណត់របស់ម្ចាស់កាត។ ការអនុញ្ញាតបន្ថែមត្រូវតែទទួលបាន និងកត់ត្រាសម្រាប់ការគិតថ្លៃដែលកើតឡើង លើសពីកម្រិតទឹកប្រាក់ដែលបានប៉ាន់ស្មាន។

ប្រការនេះ អនុវត្តចំពោះអាជីវករដែលចុះឈ្មោះប្រើប្រាស់សេវាកម្មម៉ាស៊ីនទូទាត់ POS ហើយជ្រើសរើសមុខងារ ប្រតិបត្តិការកាត់ទុក (pre-authorization) ប៉ុណ្ណោះ។

២.៣. ការដំណើរការប្រតិបត្តិការ

ក.) អាជីវករត្រូវដំណើរការប្រតិបត្តិការទូទាត់ ដើម្បីកាត់ទឹកប្រាក់ដែលបានទិញពីគណនីកាត ឬគណនីអ្នកទូទាត់ QR មុនពេលប្រគល់ទំនិញ ឬផ្តល់សេវាកម្ម។

ខ.) ក្នុងករណី អាជីវករមានចេតនា ឬមិនមានចេតនាធ្វើប្រតិបត្តិការស្នូន អាជីវករត្រូវលុបចោលប្រតិបត្តិការនោះ។ បើមិនដូច្នោះទេ អាជីវករត្រូវទទួលខុសត្រូវចំពោះប្រតិបត្តិការទូទាត់ត្រលប់ (charge-back) ដែលបណ្តាលមកពីប្រតិបត្តិការស្នូននោះ។

គ.) អាជីវករមិនត្រូវធ្វើប្រតិបត្តិការទូទាត់ណាមួយ សម្រាប់ទូទាត់/ផ្គត់ផ្គង់ទំនិញ ឬសេវាដែលអាជីវករត្រូវបានដាក់ចូលក្នុងបញ្ជី លេខកូដប្រភេទអាជីវករ (MCC) ដែលត្រូវបានអនុញ្ញាតឲ្យធ្វើប្រតិបត្តិការសោច់ប្រាក់ជាមុន។

២.៤. ការដកយកកាត និងការរក្សាទុក

អាជីវករត្រូវដកយកកាតមកវិញដោយសន្តិវិធី និងរក្សាទុកកាតដោយសុវត្ថិភាព នៅពេលអាជីវករទទួលបានការណែនាំពីធនាគារ ABA ឬនៅពេលអាជីវករជឿជាក់ថាកាតនោះ គឺជាកាតក្លែងក្លាយ ក្លែងបន្លំ បាត់ ឬត្រូវបានគេលួចយកទៅប្រើក្នុងការទូទាត់ជាមួយអាជីវកម្មរបស់ខ្លួន។ អាជីវករមិនត្រូវដកហូតកាតយកមករក្សាទុកដោយបង្កការរំខាន ឬគ្រោះថ្នាក់ដល់បុគ្គលឬទ្រព្យសម្បត្តិណាមួយឡើយ។ អាជីវករត្រូវតែជានាថា នឹងមិនឲ្យ ABA ទទួលខុសត្រូវលើការទាមទារ ការខូចខាត ឬបណ្តឹងណាមួយកើតចេញពីការគ្រោះថ្នាក់ ដែលប៉ះពាល់ដល់បុគ្គល ឬទ្រព្យសម្បត្តិ ទាក់ទងនឹងការដកហូត និងរក្សាទុកកាតនោះឡើយ។

ប្រការនេះ អនុវត្តចំពោះអាជីវករដែលចុះឈ្មោះប្រើប្រាស់សេវាកម្មម៉ាស៊ីនទូទាត់ POS ប៉ុណ្ណោះ។

៣. ការអនុញ្ញាតប្រតិបត្តិការកាត

ក.) សម្រាប់ប្រតិបត្តិការកាត អាជីវករទទួលស្គាល់ថា ការប្រតិបត្តិការនឹងត្រូវបានអនុញ្ញាត តែនៅពេលដែលគណនីរបស់ម្ចាស់កាតមានទឹកប្រាក់គ្រប់គ្រាន់ សម្រាប់ទូទាត់ថ្លៃទំនិញ/សេវាកម្មប៉ុណ្ណោះ ហើយការអនុញ្ញាតនោះមិនមែនជាការធានានៃការទូទាត់ឡើយ។ ក្នុងករណីវិក្កយបត្រម៉ាស៊ីនទូទាត់ POS មានសភាពទទេ បន្ទាប់ពីធ្វើការទូទាត់រួច នោះមានន័យថា មិនមានព័ត៌មាននៃប្រតិបត្តិការកាត បង្ហាញនៅលើវិក្កយបត្រម៉ាស៊ីនទូទាត់ POS និងមិនមានលេខកូដសម្រាប់អនុញ្ញាតប្រតិបត្តិការឡើយ ដូច្នេះអាជីវករត្រូវដំណើរការប្រតិបត្តិការទូទាត់នោះម្តងទៀត ព្រោះថាប្រតិបត្តិការពីមុន មិនទាន់ដំណើរការជោគជ័យ។

ខ.) អាជីវករត្រូវតែទទួលបានការអនុញ្ញាតសម្រាប់ប្រតិបត្តិការកាត មុននឹងប្រគល់ផលិតផល ឬផ្តល់សេវាកម្ម។ ប្រសិនបើប្រតិបត្តិការត្រូវបានបដិសេធដោយហេតុផលណាមួយ អាជីវករមិនត្រូវដំណើរការបន្តដើម្បីបំពេញបញ្ចប់ប្រតិបត្តិការឡើយ ហើយត្រូវទាក់ទងមកកាន់ធនាគារ ABA ដើម្បីទទួលប្រឹក្សា និងការណែនាំ។

គ.) អាជីវករ មិនត្រូវបំបែកប្រតិបត្តិការតែមួយ ដើម្បីទទួលបានការអនុញ្ញាតប្រតិបត្តិការពីរ ឬច្រើននោះទេ។

៤. ការទូទាត់ និងការផាត់ទាត់

ក.) អាជីវករត្រូវផាត់ទាត់ និងផ្ទេរប្រតិបត្តិការទូទាត់ប្រចាំថ្ងៃទៅធនាគារ ABA។ បើមិនដូច្នោះទេ នឹងបណ្តាលឲ្យមានប្រតិបត្តិការទូទាត់ត្រលប់ (chargeback) ហើយអាជីវករត្រូវទទួលខុសត្រូវចំពោះការសងប្រាក់សម្រាប់ប្រតិបត្តិការទូទាត់ បង្កពីការទូទាត់ និងផ្ទេរយឺតយ៉ាវរបស់អាជីវករ។ ប្រការនេះអនុវត្តចំពោះអាជីវករដែលចុះឈ្មោះប្រើប្រាស់សេវាកម្មម៉ាស៊ីនទូទាត់ POS ប៉ុណ្ណោះ។

ខ.) ធនាគារ ABA មានសិទ្ធិក្សាទុកទឹកប្រាក់ណាមួយពីប្រតិបត្តិការទូទាត់ ឬទឹកប្រាក់ផ្ទេរផ្សេងទៀតទៅកាន់គណនីអាជីវករដែលកំណត់ដោយធនាគារ ABA ។ ធនាគារ ABA នឹងបញ្ចេញទឹកប្រាក់វិញ នៅពេលធនាគារជឿជាក់ថាទឹកប្រាក់ និងការផ្ទេរប្រាក់ផ្សេងទៀត មិនជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការទូទាត់ត្រលប់ (chargeback) ការក្លែងបន្លំ និងកំហុសឆ្គង។

គ.) អាជីវករត្រូវប្រគល់ទឹកប្រាក់ប្រតិបត្តិការណាមួយ ដែលត្រូវបានស្នើសុំដោយធនាគារ ABA ពាក់ព័ន្ធនឹងប្រតិបត្តិការទូទាត់ត្រលប់ (chargeback) ឬប្រតិបត្តិការដែលមានបញ្ហា។

ឃ.) អាជីវករត្រូវតែរក្សាទុកទឹកប្រាក់ឲ្យបានគ្រប់គ្រាន់នៅក្នុងគណនីអាជីវករដែលកំណត់ដោយធនាគារ ABA ដើម្បីទូទាត់ថ្លៃសេវា ថ្លៃពិន័យ ប្រតិបត្តិការទូទាត់ត្រលប់ (chargeback) ថ្លៃបន្ទុកផ្សេងទៀត និងទឹកប្រាក់ដល់កំណត់បង់ដែលត្រូវបង់ជូនធនាគារ ABA ទាំងពេលកំពុងដំណើរការ និងបន្ទាប់ពីបញ្ចប់កិច្ចព្រមព្រៀងនេះរបស់អាជីវករ។

៥. បង្កាន់ដៃលក់ដូរ

ក.) អាជីវករត្រូវរាយមុខទំនិញ និងសេវាកម្ម ព្រមទាំងចំនួនទឹកប្រាក់សរុបដៃលបានទិញនៅក្នុងមួយប្រតិបត្តិការលក់ នៅលើឯកសារបង្កាន់ដៃលក់ដូរតែមួយ ឬកំណត់ត្រាប្រតិបត្តិការ ឬកំណត់ត្រាផ្សេងទៀត លុះត្រាតែការទូទាត់មួយផ្នែកត្រូវបានធ្វើឡើងនៅលើបង្កាន់ដៃលក់ដូរ ឬកំណត់ត្រាប្រតិបត្តិការ ឬកំណត់ត្រាផ្សេងទៀត ហើយសមតុល្យនៃប្រតិបត្តិការត្រូវបានទូទាត់ជាសាច់ប្រាក់ តាមមូលប្បទានបត្រ ឬតាមមធ្យោបាយទូទាត់ផ្សេងទៀត នៅពេលធ្វើប្រតិបត្តិការ។

ខ.) អាជីវករត្រូវប្រគល់បង្កាន់ដៃលក់ដូរនោះមួយច្បាប់ ទៅឲ្យអតិថិជនបន្ទាប់ពីបញ្ចប់ការទូទាត់រួច។ ប្រតិបត្តិការទូទាត់នីមួយៗ ដៃលអាជីវករបញ្ជូនមកធនាគារ ABA ត្រូវតែភ្ជាប់មកជាមួយឯកសារបង្កាន់ដៃលក់ដូរតែមួយ ដៃលមានឯកសារគាំទ្រផ្សេងទៀត រួមមានជាអាទិ៍៖

- បង្កាន់ដៃទូទាត់ ដៃលមានបញ្ជាក់ខ្លីៗពីទំនិញ ឬសេវាកម្មដៃលបានលក់ ឈ្មោះអាជីវកម្ម និងអត្តសញ្ញាណរបស់អាជីវករ ចំនួនទឹកប្រាក់សរុបដៃលត្រូវទូទាត់ កាលបរិច្ឆេទ និងពេលវេលានៃប្រតិបត្តិការ និងហត្ថលេខារបស់អាជីវករ និងអតិថិជន។
- បង្កាន់ដៃម៉ាស៊ីនទូទាត់ POS ដៃលបានផ្ទៀងផ្ទាត់ជាមួយលេខសម្ងាត់ ឬហត្ថលេខារបស់ម្ចាស់កាត។
- ប្រតិបត្តិការ QR, បង្កាន់ដៃអេឡិកត្រូនិកសម្រាប់ (សារ SMS ឬអ៊ីមែលបញ្ជាក់អំពីប្រតិបត្តិការទូទាត់)។
- កម្រងព័ត៌មានរបស់ភ្ញៀវ ការកក់ ឬព័ត៌មានលម្អិតនៃការកក់ ឬប័ណ្ណទឹកប្រាក់សម្រាប់ការស្នាក់នៅ និងឯកសារគាំទ្រពាក់ព័ន្ធផ្សេងទៀត (ប្រសិនបើមាន)។
- ប្រសិនបើតម្រូវដោយធនាគារ ABA អាជីវករត្រូវផ្តល់ឯកសារគាំទ្រចាំបាច់ផ្សេងទៀតដូចជា វិក្កយបត្រ បង្កាន់ដៃ និងវិញ្ញាបនបត្រពីក្រុមហ៊ុនតេស្តពិសោធឯករាជ្យណាមួយ ដើម្បីបញ្ជាក់គុណភាពផលិតផល។

ប្រសិនបើអាជីវករទទួលយកប្រតិបត្តិការ ដោយមិនទទួលបានបង្កាន់ដៃលក់ដូរ តាមលក្ខខណ្ឌតម្រូវខាងលើ និងឯកសារគាំទ្រផ្សេងទៀត នោះអាជីវករអាចធ្វើទៅបានដោយទទួលខុសត្រូវលើហានិភ័យ និងការខាតបង់ណាមួយដោយខ្លួនឯង។

៦. ការការពារអ្នកប្រើប្រាស់

អាជីវករត្រូវទទួលខុសត្រូវចំពោះព័ត៌មានអាជីវកម្មដៃលអាចទុកចិត្តបាន ដៃលត្រូវបង្ហាញដល់អ្នកប្រើប្រាស់ ឬអ្នកបង់ប្រាក់ ទោះបីជាក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ឬទម្រង់អេឡិកត្រូនិក ឲ្យមានលក្ខណៈគ្រប់គ្រាន់ ត្រឹមត្រូវ អាចអានបាន យល់បាន និងយ៉ាងហោចណាស់ ផ្តល់ព័ត៌មានទូទៅ រួមមានជាអាទិ៍៖

ក.) ឈ្មោះ ឬឈ្មោះស្របច្បាប់នៃអាជីវកម្ម អាជីវកម្មដែលបានចុះបញ្ជី និងព័ត៌មានទំនាក់ទំនង អ៊ីមែល និងលេខទូរស័ព្ទ និងប្រភេទនៃទំនាក់ទំនងតាមអេឡិកត្រូនិកផ្សេងទៀត។

ខ.) មធ្យោបាយទំនាក់ទំនងរហ័ស មានប្រសិទ្ធភាព និងងាយស្រួលសម្រាប់អាជីវករ និងអ្នកបង់ប្រាក់។

គ.) ខ និងលក្ខខណ្ឌ, តម្លៃទំនិញ ឬសេវាកម្ម និងការគិតថ្លៃពាក់ព័ន្ធផ្សេងទៀតចំពោះប្រតិបត្តិការលក់របស់អាជីវករ ជាពិសេស លក្ខខណ្ឌទូទាត់ ពាក់ព័ន្ធនឹងការលុបចោលប្រតិបត្តិការ និងគោលការណ៍សងប្រាក់, ការរក្សាទុកទឹកប្រាក់, មធ្យោបាយដឹកជញ្ជូន និងការដូរផលិតផល ឬសេវាកម្ម និង;

ឃ.) មានផលិតផល ឬសេវាកម្មសម្រាប់លក់ពិតប្រាកដ។

៧. ការរក្សាទុក និងការបញ្ជូនទិន្នន័យកាត និងបង្កាន់ដៃលក់ដូរ

ក.) អាជីវករមិនត្រូវរក្សាទុកទិន្នន័យកាត រួមមានលេខកាត កាលបរិច្ឆេទផុតកំណត់ និងលេខ CVV ឬលេខកូដ CVC និងព័ត៌មានផ្សេងទៀតដែលទាក់ទងនឹងទិន្នន័យកាត ទោះបីជាទិន្នន័យតាមអេឡិកត្រូនិក (ដូចជា spreadsheet, network drive, database server) ឬតម្រង់រូបន្ត (hard copy) នៃលិខិតអនុញ្ញាត ឬបញ្ជូន/ទទួលដោយការផ្ញើសារតាមអេឡិកត្រូនិក (ដូចជា អ៊ីមែល កម្មវិធីផ្ញើសារជាដើម)ក៏ដោយ។ ការមិនប្រតិបត្តិតាមខ និងលក្ខខណ្ឌខាងលើ អាជីវករនឹងទទួលរងនូវការដកហូតការទទួលយកអាជីវករ និងក្លាយជាកម្មវត្ថុនៃភ្នាក់ងារបំពានទិន្នន័យ។ អាជីវករត្រូវទទួលខុសត្រូវចំពោះការពិន័យទាំងអស់ដែលដាក់ចេញដោយស្ថាប័នកាត ឬប្រព័ន្ធទូទាត់ ឧបសម្ព័ន្ធ ខ។ ប្រការនេះអនុវត្តចំពោះអាជីវករដែលចុះឈ្មោះប្រើប្រាស់សេវាកម្មម៉ាស៊ីនទូទាត់ POS ប៉ុណ្ណោះ។

ខ.) អាជីវករត្រូវតែរក្សាទុកបង្កាន់ដៃលក់ដូរទាំងអស់នៅកន្លែងដែលមានសុវត្ថិភាពរយៈពេលបី (៣) ឆ្នាំក្រោយកាលបរិច្ឆេទប្រតិបត្តិការ។ ប្រសិនបើធនាគារ ABA ស្នើសុំច្បាប់ចម្លងនៃបង្កាន់ដៃលក់ដូរ ប័ណ្ណទឹកប្រាក់ឥណទាន (Credit Voucher) ឬឯកសារបញ្ជាក់អំពីប្រតិបត្តិការផ្សេងទៀត អាជីវករត្រូវផ្តល់ឯកសារទាំងនេះជូនធនាគារក្នុងរយៈពេលបី (៣) ថ្ងៃប្រតិទិន បន្ទាប់ពីកាលបរិច្ឆេទស្នើសុំ។ ការខកខានមិនផ្តល់បង្កាន់ដៃលក់ដូរមានសុពលភាព និងឯកសារបញ្ជាក់អំពីប្រតិបត្តិការផ្សេងទៀតជូនធនាគារ ABA អាចបណ្តាលឲ្យមានប្រតិបត្តិការទូទាត់ត្រឡប់ (chargeback) ហើយអាជីវករត្រូវទទួលខុសត្រូវចំពោះការខាតបង់នេះ។

៨. ការត្រលប់ និងការកែតម្រូវ

អាជីវករត្រូវបង្ហាញគោលការណ៍ទៅអ្នកបង់ប្រាក់ ជាការដោះដូរនឹងទំនិញដែលបានលក់ និងកែតម្រូវចំពោះសេវាកម្មដែលផ្តល់ជូន នៅពេលណាមួយដែលអាចអនុវត្តបាន។ ការបង្ហាញគោលការណ៍នោះ ត្រូវមានទម្រង់ជាលិខិតលាយលក្ខណ៍អក្សរ អំឡុងពេលលក់ ដើម្បីឲ្យអ្នកបង់ប្រាក់បានអាន និងចុះហត្ថលេខាលើលិខិតនោះ។ ប្រសិនបើអាជីវករមិនបានបង្ហាញនោះទេ ការបង្វិលសងប្រាក់គ្រប់ចំនួន នឹងត្រូវផ្តល់ទៅគណនីកាតរបស់ម្ចាស់កាត ក្នុងទម្រង់ដាក្រឌីត។ ក្នុងករណីមានប្រតិបត្តិការសងប្រាក់វិញ អាជីវករមិនត្រូវបង្វិលសង ឬធ្វើការទូទាត់ជាសាច់ប្រាក់ ទៅឲ្យអ្នកបង់ប្រាក់ ដែល

ទូទាត់ថ្លៃទំនិញនោះទេ ពោល អាជីវករត្រូវផ្ទេរទឹកប្រាក់នោះ ទៅលេខគណនីអ្នកបង់ប្រាក់ ដែលលេខគណនី ដូចគ្នានឹងគណនីប្រើសម្រាប់ធ្វើប្រតិបត្តិការលក់ពីដំបូង ។

៩. ការទទួលខុសត្រូវចំពោះប្រតិបត្តិការទូទាត់

អាជីវករត្រូវទទួលខុសត្រូវចំពោះការទទួលយក ឬការបដិសេធនៃប្រតិបត្តិការទូទាត់ទាំងអស់ ។ ធនាគារ ABA នឹងមិនទទួលខុសត្រូវចំពោះការខាតបង់, ក្លែងបន្លំ, ប្រតិបត្តិការទូទាត់ត្រលប់ (chargeback), ការមិនប្រតិបត្តិតាម ឬប្រតិបត្តិការណាមួយ ដែលបណ្តាលមកពីការទទួលយកប្រតិបត្តិការរបស់អាជីវករឡើយ ។ អាជីវករត្រូវព្យាយាមដោះស្រាយរាល់ការស្នើសុំ ការទាមទារ ឬការតវ៉ា ដែលលើកឡើងដោយអ្នកបង់ប្រាក់ ទាក់ទងនឹងផលិតផល និងសេវាកម្មរបស់អាជីវករ ។ ប្រសិនបើអាជីវករមិនអាចដោះស្រាយការស្នើសុំ ការទាមទារ ឬការតវ៉ារបស់អតិថិជនបានទេ អាជីវករត្រូវរ៉ាប់រង និងទូទាត់រាល់ទឹកប្រាក់ដែលទាមទារដោយអតិថិជន ។ ទោះជាយ៉ាងនេះក្តី ធនាគារ ABA អាចប្រឹក្សាជូនអាជីវករចំពោះកាត និង QR របស់អតិថិជន ម្តងម្កាល នៅពេលអាជីវករមានចម្ងល់ ហើយទាក់ទងទៅធនាគារ ABA ដើម្បីស្នើឲ្យធនាគារជួយ ដែលការជួយនោះ ធនាគារ ABA នឹងធ្វើឡើងតែក្នុងលក្ខខណ្ឌដែលធនាគារមិនបំពានលើកាតព្វកិច្ចរក្សាការសម្ងាត់ ឬកាតព្វកិច្ចមិនបង្ហាញព័ត៌មានអតិថិជន ។

១០. ការអនុលោមតាមច្បាប់

ក.) អាជីវករត្រូវគោរពតាមច្បាប់ លក្ខន្តិក: វិធាន បទប្បញ្ញត្តិទាំងឡាយដែលកំណត់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងស្តាប់នាកាត ព្រមទាំងអនុលោមតាមបទដ្ឋានសន្តិសុខទិន្នន័យឧស្សាហកម្មកាតទូទាត់, ការមិនបង្ហាញ និងរក្សាទុកព័ត៌មានម្ងាស់កាត និងទិន្នន័យប្រតិបត្តិការនៅគ្រប់កាល:ទេស: ។ ទោះជាយ៉ាងណាក៏ដោយ អាជីវករអាចរក្សាទុកព័ត៌មានរបស់ម្ងាស់កាតឲ្យមានសុវត្ថិភាព ដូចជារបាយការណ៍ប្រតិបត្តិការ បង្កាន់ដៃប្រតិបត្តិការ ឯកសារបង្កាន់ដៃលក់ដូរ ដែលអាចចាំបាច់សម្រាប់អាជីវកម្មរបស់អាជីវករ និងអនុញ្ញាតឲ្យចូលប្រើសម្រាប់តែបុគ្គលិកដែលមានការអនុញ្ញាតប៉ុណ្ណោះ ។

ខ.) អាជីវករមិនត្រូវទាមទារព័ត៌មានផ្ទាល់ខ្លួនណាមួយរបស់អតិថិជន ដូចជាអត្តសញ្ញាណផ្ទាល់ខ្លួន លិខិតឆ្លងដែន ប័ណ្ណបើកបរ អាសយដ្ឋានផ្ទះ ឬអាជីវកម្ម និងលេខទូរស័ព្ទ លុះត្រាតែមានការណែនាំដោយធនាគារ ABA និងប្រតិបត្តិការដែលតម្រូវឲ្យផ្តល់ព័ត៌មានទាំងនោះ ។

គ.) អាជីវករអាចមើលឃើញតែលេខគណនីដែលបានបំប្លែង (encrypted) នៅលើបង្កាន់ដៃប៉ុណ្ណោះ ឬអាជីវករអាចប្រើផ្នែកមួយនៃលេខគណនី ដែលព្រឹនប្រាំមួយ (៦) ខ្ទង់ដំបូង ឬពីរបីខ្ទង់ចុងក្រោយនៃលេខគណនីនៅលើបង្កាន់ដៃ ។ កថាខណ្ឌ (គ) នេះអនុវត្តចំពោះអាជីវករដែលចុះឈ្មោះប្រើប្រាស់សេវាកម្មម៉ាស៊ីនទូទាត់ POS ប៉ុណ្ណោះ ។

ឃ.) អាជីវករត្រូវកម្ទេចចោលដោយសុវត្ថិភាពនូវរាល់មេឌាទាំងអស់ ដែលផ្ទុកទិន្នន័យប្រតិបត្តិការជាមួយព័ត៌មានម្ងាស់កាតដែលលែងត្រូវការសម្រាប់អាជីវកម្មរបស់អាជីវករ ។

ង.) អាជីវករត្រូវតែជូនដំណឹងដល់ធនាគារ ABA សម្រាប់ភ្នាក់ងារណាមួយ រួមមានអ្នកដំណើរការប្រព័ន្ធ អ្នកលក់ អ្នកផ្គត់ផ្គង់សូហ្វ៊ែរ មធ្យោបាយទូទាត់ ឬអ្នកផ្តល់សេវាកម្មផ្សេងទៀត ដែលអាជីវករចូលរួមក្នុងដំណើរការ ឬការផ្ទេរទិន្នន័យប្រតិបត្តិការ។ លើសពីនេះអាជីវករត្រូវតែធានាថា ភ្នាក់ងារបំពេញតាមតម្រូវការសុវត្ថិភាពកាតទាំងអស់សម្រាប់ការការពារទិន្នន័យម្ចាស់កាត។ កថាខណ្ឌ (ង) នេះអនុវត្តចំពោះអាជីវករដែលចុះឈ្មោះប្រើប្រាស់សេវាកម្មម៉ាស៊ីនទូទាត់ POS ប៉ុណ្ណោះ។

ច.) អាជីវករត្រូវជូនដំណឹងមកធនាគារ ABA ភ្លាមៗ ប្រសិនបើទិន្នន័យប្រតិបត្តិការណា មួយត្រូវបានចូលប្រើ ឬទាញយក ដោយអង្គភាពដែលមិនមានការអនុញ្ញាត ហើយអាជីវករត្រូវមាននីតិវិធី និងប្រព័ន្ធរួចជាស្រេច ដើម្បីបញ្ឈប់ការប្រើប្រាស់ទិន្នន័យដែលគ្មានការអនុញ្ញាត។ កថាខណ្ឌ (ច) នេះអនុវត្តចំពោះអាជីវករដែលចុះឈ្មោះប្រើប្រាស់សេវាកម្មម៉ាស៊ីនទូទាត់ POS ប៉ុណ្ណោះ។

១១. អាជីវកម្មរបស់អាជីវករ

អាជីវករត្រូវផ្តល់ដំណឹងមកធនាគារ ABA ជាបន្ទាន់ ចំពោះស្ថានភាពណាមួយខាងក្រោម៖

ក.) ការផ្លាស់ប្តូរលក្ខណៈដើមនៃអាជីវកម្មរបស់អាជីវករ ដូចជាការលក់ទំនិញ ឬសេវាកម្មណាមួយដែលមិនទាក់ទងនឹងអាជីវកម្មបច្ចុប្បន្នរបស់អាជីវករ។

ខ.) ការផ្ទេរការគ្រប់គ្រងនៃអាជីវកម្មរបស់អាជីវករ, ប្តូរម្ចាស់កម្មសិទ្ធិ បញ្ចប់ភាពជាដៃគូ ឬបិទអាជីវកម្ម។

គ.) ការលក់ ឬផ្ទេរផ្នែកសំខាន់ណាមួយនៃទ្រព្យសកម្មសរុប របស់អាជីវកម្ម។

ឃ.) ការផ្លាស់ប្តូរព័ត៌មានរបស់អាជីវករ ទាក់ទងនឹងលក្ខខណ្ឌ/ស្ថានភាពហិរញ្ញវត្ថុ សកម្មភាពបទប្បញ្ញត្តិ ដែលអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិ និងផលប្រយោជន៍របស់ធនាគារ ABA នៅក្នុងកិច្ចព្រមព្រៀងនេះ។

ង.) ការបង្កើតការិយាល័យ/សាខាបន្ថែម ឬអាជីវកម្មថ្មី, អត្តសញ្ញាណរបស់អ្នកតំណាង និង/ឬម្ចាស់អាជីវកម្ម, ទម្រង់នៃការរៀបចំ និងការប្រព្រឹត្តទៅនៃអាជីវកម្ម, ប្រភេទទំនិញ និងសេវាកម្មដែលផ្តល់ជូន។

ប្រសិនបើអាជីវករមិនបានជូនដំណឹងនោះទេ ធនាគារ ABA អាចផ្អាកទឹកប្រាក់ កែប្រែកាលវិភាគផ្តល់ទឹកប្រាក់ ឬបញ្ចប់កិច្ចព្រមព្រៀងនេះនៅពេលណាក៏បាន។ លើសពីនេះ អាជីវករត្រូវទទួលខុសត្រូវចំពោះការខាតបង់ និងការចំណាយនានារបស់ធនាគារ ABA ដែលបណ្តាលមកពីការខកខានមិនបានរាយការណ៍អំពីស្ថានភាពណាមួយដែលបានរៀបរាប់ខាងលើ។ ធនាគារ ABA ក៏អាចនឹងបញ្ចប់កិច្ចព្រមព្រៀងនេះភ្លាមៗផងដែរ ចំពោះការផ្លាស់ប្តូរណាមួយខាងលើ មិនថាការផ្លាស់ប្តូរនោះត្រូវបានរកឃើញដោយធនាគារ ABA ផ្ទាល់ ឬត្រូវបានជូនដំណឹងដោយអាជីវករនោះទេ។

១២. ការផ្សព្វផ្សាយ និងប្រូម៉ូសិន

អាជីវករត្រូវដាក់តាំងសម្ភារៈផ្សព្វផ្សាយណាមួយដែលផ្តល់ដោយធនាគារ ABA នៅទីតាំងធ្វើអាជីវកម្ម របស់ខ្លួន រួមមាន ឈ្មោះអាជីវកម្ម សញ្ញាសេវាកម្ម ពាណិជ្ជសញ្ញា ឬប្រភេទឡូហ្គូដែលភ្ជាប់ជាមួយ កាត និង ABA QR ដើម្បីជូនដំណឹងដល់សាធារណជនថា ទីតាំងរបស់ខ្លួនទទួលយកការទូទាត់តាម កាត និង ABA QR។ ទោះជាយ៉ាងនេះក្តី អាជីវករត្រូវឈប់ប្រើប្រាស់ភ្លាមៗ ហើយប្រគល់សម្ភារៈ ទាំងនោះឲ្យធនាគារ ABA វិញ ប្រសិនបើមានការស្នើសុំ ឬនៅពេលកិច្ចព្រមព្រៀងនេះត្រូវបាន បញ្ចប់។ អាជីវករត្រូវទទួលខុសត្រូវចំពោះការខាតបង់ ការខូចខាត ឬការចំណាយនានារបស់ធនាគារ ABA ក្នុងអំឡុងពេលប្រើប្រាស់ ឬបណ្តាលមកពីការមិនប្រគល់ ឬបំផ្លាញសម្ភារៈទាំងនោះ បន្ទាប់ពី មានការស្នើសុំពីធនាគារ ABA។

១៣. ការជូនដំណឹងអំពីកំហុសឆ្គង

អាជីវករត្រូវពិនិត្យភ្លាមៗ និងជាប្រចាំនូវរាល់ព័ត៌មានអំពីប្រតិបត្តិការនានាដែលធនាគារ ABA ផ្ញើទៅ អាជីវករ ហើយត្រូវជូន ដំណឹងមកធនាគារ ABA ជាបន្ទាន់ ប្រសិនបើកំណត់ត្រាលក់របស់ខ្លួន និង កំណត់ត្រាដែល ABA បានផ្តល់ជូនមិនត្រូវគ្នា ឬពាក់ព័ន្ធនឹងការផ្ទេរប្រាក់ណាមួយ ដែលអាជីវករ ជឿថា មិនត្រូវបានអនុញ្ញាតដោយអាជីវករ ឬអតិថិជនផ្ទាល់។ ប្រសិន បើអាជីវករខកខានមិនបាន ជូនដំណឹងជាលាយលក្ខណ៍អក្សរមកធនាគារ ABA ក្នុងរយៈពេលបី (3) គិតចាប់ពីថ្ងៃដែលទិន្នន័យ ឬព័ត៌មានបានផ្ញើទៅអាជីវករ នោះអាជីវករត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការខាតបង់ ឬការ ចំណាយផ្សេងទៀតពាក់ព័ន្ធ នឹងកំហុសឆ្គងនោះ។

១៤. វិសោធនកម្មលើកិច្ចព្រមព្រៀង

ធនាគារ ABA រក្សាសិទ្ធិក្នុងការកែប្រែ និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ ម្តងម្កាល រួមមានជាអាទិ៍ ថ្លៃសេវា និងការគិតថ្លៃផ្សេងទៀត ដោយជូនដំណឹងទៅអាជីវករជាលាយលក្ខណ៍អក្សរ។ រាល់ការ កែប្រែណាមួយពីធនាគារ ABA ត្រូវបានទទួលយក និងអនុវត្តដោយអាជីវករក្នុងរយៈពេលបី (03) ថ្ងៃ ក្រោយពីកាលបរិច្ឆេទជូនដំណឹង លើកលែងតែធនាគារ ABA ទទួលបានការជូនដំណឹងណាមួយ ពាក់ព័ន្ធនឹងការបដិសេធលើការកែប្រែណាមួយនៃខ និងលក្ខខណ្ឌក្រោមកិច្ចព្រមព្រៀងនេះ។

១៥. ការធានា

អាជីវករធានាជូន ABA ថា៖

ក.) នៅពេលអនុវត្ត និងក្នុងអំឡុងពេលអនុវត្តលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ អាជីវករធានាថា ព័ត៌មាន ទាំងអស់ នៅក្នុង ពាក្យស្នើសុំអាជីវករ ឬឯកសារផ្សេងទៀត ដែលបានប្រគល់ជូន ធនាគារ ABA គឺ ពិតប្រាកដ និង ត្រឹមត្រូវ ហើយព័ត៌មានទាំងនោះ ឆ្លុះបញ្ចាំងទាំងស្រុង និងត្រឹមត្រូវអំពីប្រតិបត្តិការ អាជីវកម្មរបស់អាជីវករ។។

ខ.) បុគ្គលដែលអនុវត្តកិច្ចព្រមព្រៀងនេះ ត្រូវបានអនុញ្ញាតយ៉ាងត្រឹមត្រូវ និងមានសមត្ថកិច្ចផ្នែកច្បាប់ក្នុង ការចងភ្ជាប់ អាជីវករទៅនឹងបទប្បញ្ញត្តិទាំងអស់នៃកិច្ចព្រមព្រៀងនេះ។

គ.) បុគ្គលនោះ ត្រូវបានអនុញ្ញាតឲ្យអនុវត្តឯកសារណាមួយ និងចាត់វិធានការណាមួយជំនួស/តំណាងឲ្យ អាជីវករ ដែលអាចតម្រូវដោយធនាគារ ABA នៅពេលនេះ ឬនៅពេលក្រោយ។

ឃ.) ផ្តល់ព័ត៌មានត្រឹមត្រូវ និងច្បាស់លាស់នៃទំនិញ ឬសេវាកម្មរបស់ខ្លួន ទៅអ្នកបង់ប្រាក់ជាមុន មុនពេលប្រតិបត្តិការទូទាត់ចាប់ផ្តើម។

ង.) ផ្តល់ ឬចែកចាយទំនិញ ឬសេវាកម្ម ដោយអនុលោមយ៉ាងពេញលេញតាមលក្ខខណ្ឌលក់ និងកិច្ចសន្យាលក់។

ច.) ធានាថាទំនិញ ឬសេវាកម្មមិនស្ថិតក្នុងសភាពខូចខាត ឬក្នុងសភាពដែលមិនបានបញ្ជាក់ក្នុងកិច្ចសន្យាលក់។

ឆ.) ឆ្លើយតបទៅនឹងសំណួររបស់អ្នកបង់ប្រាក់ ឬការតវ៉ាណាមួយដែលកើតឡើងទាក់ទងនឹងទំនិញ ឬសេវាកម្មដែលបានលក់។

ជ.) ផ្តល់បង្កាន់ដៃលក់ដូរ ឬឯកសារពាក់ព័ន្ធនឹងការលក់ ប្រសិនបើមានសំណើសុំច្បាប់ចម្លងពី ABA ឬអ្នកបង់ប្រាក់។

ឈ.) អាជីវករត្រូវតែចូលរួមដោះស្រាយវិវាទ ដែលតវ៉ាដោយអតិថិជន មិនថាក្នុងអំឡុងកំពុងអនុវត្តកិច្ចព្រមព្រៀង ឬបន្ទាប់ពីការបញ្ចប់កិច្ចព្រមព្រៀងនេះ

១៦. ការបញ្ចប់កិច្ចព្រមព្រៀង និងវិបាក

ក.) កិច្ចព្រមព្រៀងនេះ អាចត្រូវបានបញ្ចប់ដោយធនាគារ ABA គ្រប់ពេលវេលា ដោយមាន ឬមិនមានមូលហេតុ និងដោយមិនជូនដំណឹងជាមុនឡើយ ឬនៅពេលអាជីវករបង្កកំហុសឆ្គងដូចមានកំណត់ក្នុងផ្នែកទី១២, ១៣ និង ១៤ នៃកិច្ចព្រមព្រៀងនេះ។

ខ.) ABA មានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះ ប្រសិនបើអាជីវករមានប្រតិបត្តិការតិចជាងប្រាំ (៥) ប្រតិបត្តិការក្នុងរយៈពេលសាមសិប (៣០) ថ្ងៃប្រតិទិនជាប់ៗគ្នា។ ក្នុងករណីនេះ ABA នឹងជូនដំណឹងដល់អាជីវករអំពីបរិមាណទាបនៃប្រតិបត្តិការនោះ បន្ទាប់ពីសាមសិប (៣០) ថ្ងៃប្រតិទិនដំបូង និងតាមដានបរិមាណប្រតិបត្តិការអំឡុងពេល ៣០ ថ្ងៃ បន្ទាប់។ ABA មានសិទ្ធិសម្រេចបញ្ចប់កិច្ចព្រមព្រៀង បន្ទាប់ពីរយៈពេលសាមសិប (៣០) ថ្ងៃដំបូងនេះ ដោយខ្លួនឯង ហើយមានកាតព្វកិច្ចជូនដំណឹងដល់អាជីវករក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃប្រតិទិន មុនសម្រេចបញ្ចប់កិច្ចព្រម ព្រៀង។

គ.) ក្នុងករណីបញ្ចប់កិច្ចព្រមព្រៀងដោយគ្មានមូលហេតុ ធនាគារ ABA ត្រូវបានអនុញ្ញាតក្នុងការរក្សាទុក និងបញ្ឈប់ ការទូទាត់រាល់ប្រតិបត្តិការទូទាត់ និងប្រតិបត្តិការទូទាត់ផ្សេងទៀតរបស់អាជីវករដែលស្ថិតក្នុងដំណើរការនៃការ ប្រមូល និងដាក់ប្រាក់ រហូតដល់អាជីវករធ្វើការទូទាត់រួចរាល់នូវថ្លៃសេវា និងថ្លៃបន្ទុក ការខាតបង់ ឬទឹកប្រាក់ សេសសល់ណាមួយដែលមិនទាន់បង់ ដែលអាជីវករទទួលខុសត្រូវ

ក្រោមកិច្ចព្រមព្រៀងនេះ។ លើសពីនេះ ធនាគារ ABA រក្សាសិទ្ធិក្នុងការតម្រូវឲ្យអាជីវករដាក់ប្រាក់បន្ថែម ៣ក់ព័ន្ធនឹងវិវាទ, ការក្លែងបន្លំ, ការខាតបង់របស់ម្ចាស់កាត ព្រមទាំងចំនួនទឹកប្រាក់ផ្សេងទៀត ដែលដល់ពេលកំណត់ និងត្រូវបង់ជូនធនាគារ ABA។

ឃ.) ប្រសិនបើកិច្ចព្រមព្រៀងនេះត្រូវបានបញ្ចប់ដោយមូលហេតុណាមួយដោយធនាគារ ABA ឬប្រសិនបើអាជីវករមានបំណងចង់បញ្ចប់កិច្ចព្រមព្រៀងនេះ អាជីវករទទួលស្គាល់ថាធនាគារ ABA អាចរាយការណ៍អំពីឈ្មោះអាជីវករ និងឈ្មោះអាជីវកម្មរបស់អាជីវករ និងព័ត៌មានគោល ឬតំណាងផ្សេងទៀតរបស់អាជីវករ ទៅកាន់ឯកសារ/ឯកសារ MACH របស់អាជីវករដែលត្រូវបញ្ចប់ ដែលរក្សាទុកដោយស្ថាប័នកាត ឬប្រសិនបើហេតុផលបែបនេះកើតឡើង នៅពេលអាជីវករសម្រេចបញ្ចប់កិច្ចព្រមព្រៀងនេះដោយស្ម័គ្រចិត្ត។ លើសពីនេះ អាជីវករយល់ព្រមបោះបង់សិទ្ធិទាមទារការខូចខាត ឬធានាមិនឲ្យ ABA ទទួលខុសត្រូវចំពោះការទាមទារណាមួយ ដែលអាជីវករអាចប្រឈមបណ្តាលមកពីការរាយការណ៍បែបនេះ។

ង.) កិច្ចព្រមព្រៀងនេះ ត្រូវបានផ្តាក ឬបញ្ចប់ភ្លាមៗ ប្រសិនបើអាជីវករត្រូវបានរកឃើញតាមរយៈសវនកម្ម ឬការស៊ើបអង្កេតដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ធនាគារ ABA ឬអ្នកស៊ើបអង្កេត ឬសវនកម្មឯករាជ្យសហការជាមួយ ធនាគារ ABA ថាអាជីវករបានចូលរួមក្នុងសកម្មភាពក្លែងបន្លំ។

ច.) ការបញ្ចប់ប្រូម៉ូសិនមុនកាលកំណត់ អាចធ្វើឡើងនៅពេលធនាគារ ABA បានទទួលការជូនដំណឹងជាលាយ លក្ខណ៍អក្សរអំពីការបញ្ចប់កម្មវិធីប្រូម៉ូសិននៃកិច្ចព្រមព្រៀងនេះ៖ ពីអាជីវករ មិនតិចជាងសាមសិប (៣០) ថ្ងៃប្រតិទិន មុនថ្ងៃដែលអាជីវកររស្នើសុំបញ្ចប់។ លើសពីនេះ កិច្ចព្រមព្រៀងនេះអាចត្រូវបានបញ្ចប់គ្រប់ពេលវេលាដោយធនាគារ ABA ដោយមាន ឬមិនមានមូលហេតុ និងដោយមិនជូនដំណឹងជាមុន ឬនៅពេលដែលអាជីវករបំពានផ្នែកណាមួយនៃលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។

១៧. សំណង និងការទទួលខុសត្រូវមានកម្រិត

ក.) អាជីវកររយល់ព្រមផ្តល់សំណង និងធានាថាធនាគារ ABA និងបុត្រសម្ពន្ធ ភ្នាក់ងារ បុគ្គលិក និងប្រធានគ្រប់គ្រងរបស់ខ្លួន មិនរងផលប៉ះពាល់ ពីការខាតបង់ ការទាមទារ បំណុល ការខូចខាត ការចំណាយ ការពិន័យ និងផាកពិន័យ រួមទាំងថ្លៃសេវាផ្នែកច្បាប់ ដែលបណ្តាលមកពី ឬទាក់ទងនឹងកិច្ចព្រមព្រៀងនេះ ឬកើតចេញពីសកម្មភាពក្លែងបន្លំ ការធ្វេសប្រហែស ឬការប្រព្រឹត្តដោយចេតនារបស់អាជីវករ, បុគ្គលិករបស់អាជីវករ ភ្នាក់ងាររបស់អាជីវករ រួមមានជាអាទិ៍ ការទាមទាររបស់ភាគីទីបីដែលបណ្តាលមកពី ឬទាក់ទងនឹងផលិតផល និងសេវាកម្មរបស់អាជីវករ។

ខ.) ធនាគារ ABA នឹងមិនទទួលខុសត្រូវចំពោះការអាក់រអួល សេវាទូរស័ព្ទ ការបំផ្លិចបំផ្លាញ ចោរកម្ម ឬមូលហេតុផ្សេងទៀតតាមលក្ខណៈធម្មជាតិ ដែលកើតចេញពី ឬពាក់ព័ន្ធនឹងភាពអាក់រអួលនៃសេវាដំណើរការកាតរបស់ធនាគារ ABA ហើយធនាគារ ABA នឹងមិនទទួលខុសត្រូវចំពោះឧប្បត្តិហេតុណាមួយ ការខូចខាតពិសេស រួមមានការខាតបង់ប្រាក់ចំណេញ ប្រាក់ចំណូល សុវ៊ែ ឬទិន្នន័យ។ ក្នុងករណីផ្សេងទៀត អាជីវករយល់ព្រមបោះបង់សិទ្ធិក្នុងការទាមទារសំណងពីធនាគារ ABA។

១៨. ការផ្ទេរសិទ្ធិបន្ត

រាល់ការផ្ទេរសិទ្ធិបន្តនៃកិច្ចព្រមព្រៀងនេះដោយអាជីវករ រួមទាំងសិទ្ធិ និងកាតព្វកិច្ចដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ តម្រូវឲ្យមានការយល់ព្រមជាមុនពីធនាគារ ABA។ ទោះជាយ៉ាងនេះក្តី ធនាគារ ABA រក្សាសិទ្ធិក្នុងការផ្ទេរ និង/ឬចាត់ចែងសិទ្ធិរបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងនេះ ទៅភាគីទីបីណាមួយ ដោយមិនចាំបាច់ទទួលការយល់ព្រមពីអាជីវកឡើយ។

១៩. កិច្ចព្រមព្រៀងទាំងស្រុង

កិច្ចព្រមព្រៀងនេះ បង្កើតបានជាកិច្ចព្រមព្រៀងទាំងស្រុងរបស់ភាគីទាំងពីរ។ កិច្ចព្រមព្រៀងណាមួយពីមុន ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ដែលផ្ទុយនឹងកិច្ចព្រមព្រៀងនេះ នឹងត្រូវចាត់ទុកជាមោយ:។

២០. អសុពលភាពដោយផ្នែក

ប្រសិនបើ នៅពេលណាមួយ បទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ ត្រូវបានធ្វើឡើងដោយមិនស្របនីតិវិធីច្បាប់ អសុពលភាព ឬមិនអាចអនុវត្តបាន ក្រោមច្បាប់គ្រប់គ្រង នោះភាពមិនស្របនីតិវិធីច្បាប់ អសុពលភាព ឬមិនអាចអនុវត្តបាននៃបទប្បញ្ញត្តិនោះនឹងមិនប៉ះពាល់ដល់បទប្បញ្ញត្តិផ្សេងឡើយ ហើយត្រូវបកស្រាយ និងចាត់ទុកថា បទប្បញ្ញត្តិ ឬចំណុចនានាដែលមិនស្របតាមនីតិវិធីច្បាប់ អសុពលភាព ឬមិនអាចអនុវត្តបានទាំងនោះ មិនមានវត្តមាននៅក្នុងកិច្ចព្រមព្រៀងនេះ។

២១. ច្បាប់គ្រប់គ្រង

កិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយ និងអនុវត្តស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

២២. ការដោះស្រាយវិវាទ

រាល់វិវាទ ភាពចម្រូងចម្រាស ឬការទាមទារណាមួយដែលកើតចេញពី ឬពាក់ព័ន្ធនឹងការបំពាន ការបញ្ចប់ ឬអសុពលភាពនៃកិច្ចព្រមព្រៀងនេះ នឹងត្រូវដោះស្រាយដោយធ្វើការចរចាឡើងវិញដោយសន្តិវិធីរវាងអាជីវករ និងធនាគារ ABA។ ប្រសិនបើការចរចានោះមិនទទួលបានជោគជ័យក្នុងរយៈពេលដប់បួន (១៤) ថ្ងៃធ្វើការ ក្រោយពីបានទទួលការជូនដំណឹងអំពីវិវាទដោយភាគីណាមួយ វិវាទ ភាពចម្រូងចម្រាស ឬការទាមទារនោះនឹងត្រូវបញ្ជូនទៅតុលាការមានសមត្ថកិច្ចនៃប្រទេសកម្ពុជាដើម្បីធ្វើការដោះស្រាយចុងក្រោយ។

ខ្ញុំ ម្ចាស់ហត្ថលេខា ដែលជាអ្នកតំណាងមានសិទ្ធិអនុញ្ញាតត្រឹមត្រូវ របស់ _____
_____ទទួលយក និងយល់ព្រមតាមខ និងលក្ខខណ្ឌខាងលើ។

ហត្ថលេខា៖ _____
ឈ្មោះ៖ _____
តួនាទី៖ _____
កាលបរិច្ឆេទ៖ _____

ឧបសម្ពន្ធ ក

ការគិតថ្លៃបន្ថែម និងការកម្រិតទឹកប្រាក់លើកាតទូទាត់

ការស្នងមតិទីផ្សារបានបង្ហាញឲ្យឃើញថាមានស្ថាប័ន/ក្រុមហ៊ុនមួយចំនួន បានកំណត់កម្រិតទឹកប្រាក់សម្រាប់ទូទាត់ និង/ឬគិតថ្លៃបន្ថែមពីអតិថិជនសម្រាប់ការទូទាត់តាមកាត។ យើងខ្ញុំសូមបញ្ជាក់ថា ការអនុវត្តបែបនេះគឺ បំពានលើលក្ខខណ្ឌនៃកិច្ចព្រមព្រៀងរបស់អ្នកជាមួយធនាគារ។ សូមយោងលើប្រការ ២.១ ការទទួលយកការទូទាត់ នៃកិច្ចព្រមព្រៀងអាជីវករ ដែលបានចុះហត្ថលេខាជាមួយធនាគារ។

ប្រសិនបើស្ថាប័ន/ក្រុមហ៊ុនរបស់អ្នកត្រូវបានគេរកឃើញថាមាន កំណត់កម្រិតទឹកប្រាក់សម្រាប់ការទូទាត់ ឬគិតថ្លៃណាមួយបន្ថែម យើងខ្ញុំនឹងផ្អាកកិច្ចព្រមព្រៀងភ្លាមៗ និងពិន័យជាទឹកប្រាក់ចំនួន USD 10,000 (មួយម៉ឺនដុល្លារ) ពីអ្នក។

សម្រាប់ការផ្អាកកិច្ចព្រមព្រៀងនេះ សូមជម្រាបថា នឹងមិនមានធនាគារណាមួយផ្សេងផ្តល់សេវាកម្មនេះជូនអ្នកឡើយ ប៉ុន្តែអ្នកអាចបន្តសេវាកម្មនេះឡើងវិញជាមួយធនាគារយើងបាន នៅពេលអ្នកផ្តល់ការបញ្ជាក់ជាលាយលក្ខណ៍អក្សរថា អតិថិជនរបស់អ្នកនឹងមិនត្រូវបានគិតថ្លៃបន្ថែម និងមិនត្រូវបានកំណត់កម្រិតទឹកប្រាក់សម្រាប់ការទូទាត់។

ឧបសម្ពន្ធ ខ

ការបំពានសុវត្ថិភាពទិន្នន័យ

ប្រសិនបើធនាគារ ABA រកឃើញថា អាជីវកម្មរបស់អាជីវករបំពានលើទិន្នន័យយោងតាម ប្រការ ៥. ការរក្សាទុក និងការបញ្ជូនទិន្នន័យកាត និងបង្កាន់ដៃលក់ដូរ អាជីវករត្រូវតែទទួលខុសត្រូវចំពោះការពិន័យដែលដាក់ចេញដោយស្ថាប័នកាត ឬប្រព័ន្ធទូទាត់ដូចខាងក្រោម៖

ប្រតិបត្តិការផ្អែកលើកាត

ទំហំប្រតិបត្តិការរបស់អាជីវករ ប្រចាំឆ្នាំ (គិតជាដុល្លារអាមេរិក)	ប្រតិបត្តិការខ្សែម៉ាញេទិក	ប្រតិបត្តិការ EMV Chip
០ - ២០០ លាន	៦,២៥%	៧,២៥%
២០១ លាន - ១ ពាន់លាន	៤,០០%	៥,០០%
លើសពី ១ ពាន់លាន	២,៧០%	៣,៧៥%

Merchant Service T&C V1_kh 11/27/25

អគារលេខ ១៤១, ១៤៦, ១៤៨, ១៤៨ អា បេ សេ ដេ និង១៦២ អា មហាវិថីព្រះសីហនុ និង
អគារលេខ ១៥ និង ១៥៣ អា បេ រ្ស ផ្លូវលេខ ២៧៨ និង អគារលេខ ១៧១ ផ្លូវត្រសក់ផ្អែម
ភូមិ៤ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

១ ៨០០ ២០៣ ២០៣ (ប្រព័ន្ធទូរស័ព្ទឥតគិតថ្លៃ) | (+៨៥៥) ៩៨ ២០៣ ៣៣៣
info@ababank.com | www.ababank.com | **SWIFT: ABAAKHPP**